ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២២០/១៦ - អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ២
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ុន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ិន គឹមស៊ាន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ២**
អាសយដ្ឋាន ៖ ផ្លូវលេខ៣៧១ ភូមិប្ញស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩៦ ២៦០០ ០៩២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក តាំង ម៉េង | ទីប្រឹក្សាក្រុមហ៊ុន |
| ២- លោក ឡេង មិនា | ប្រធានរដ្ឋបាល |
| ៣- កញ្ញា ចាន់ សំណាង | ជំនួយការរដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី**
- **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ២.៣G ផ្លូវ២៦BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៥០៤ ១៥៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | ប្រធានលេខាធិការដ្ឋានវិវាទសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក ឈីន ធា | មន្ត្រីច្បាប់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- កញ្ញា ទេព ភារ៉ូ | មន្ត្រីស្ម័គ្រចិត្តសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៤- លោក ស៊ឹម សុខា | ជាងម៉ាស៊ីន |
| ៥- កញ្ញា អន វន្ធា | លេខាធិការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ |
| ៦- លោកស្រី ស៊ាន សុផល | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកបន្តកិច្ចសន្យាជូនលោក ស៊ឹម សុខា អត្តលេខ ១៤៥៤១ ព្រមទាំងរក្សាតួនាទី ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដូចដើម ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនទទួលយកលោក ស៊ឹម សុខា ចូលធ្វើការវិញទេ តែក្រុមហ៊ុនយល់ព្រមទូទាត់ប្រាក់បំណាច់កិច្ចសន្យា និងអត្ថប្រយោជន៍ផ្សេងៗ តាមច្បាប់ស្តីពីការងារ ។

២- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតខ្ចីលុយ ឬបើកប្រាក់ឈ្នួល ៥០ ភាគរយ នៅវេលារាល់ថ្ងៃបុណ្យជាតិម្តងៗ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមសេចក្តីជូនដំណើងរបស់ក្រសួង ។

៣- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកអនុញ្ញាតច្បាប់ដល់កម្មការិនីដែលមានផ្ទៃពោះ សុំច្បាប់មុនសម្រាលកូនមួយ (០១) ខែ និងក្រោយសម្រាលកូនរួចមួយ (០១) ខែ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពិនិត្យមើលតាមការជាក់ស្តែង ។

៤- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកកុំតឹងរ៉ឹងច្បាប់ហួសហេតុពេក ដោយសុំអនុញ្ញាតឱ្យកម្មករនិយោជិតដែលឈប់សម្រាកត្រឹមពីរ (០២) ថ្ងៃ មិនបាច់មានសំបុត្រពេទ្យ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុញ្ញាតច្បាប់តាមការជាក់ស្តែង ។

៥- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកដំឡើងតម្លៃបុងឱ្យបានគ្រប់មុខងារ និងមែងចែកលេខកាតឱ្យបានគ្រប់មុខងារ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនរក្សាគោលការណ៍ចាស់ ។

៦- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកបូកបន្ថែមប្រាក់ឈ្នួលគោល ដែលបានដំឡើងនៅឆ្នាំ ២០១៥ និងឆ្នាំ២០១៦ ចូលប្រាក់ឈ្នួលគោលដែលមានស្រាប់ឱ្យកម្មករនិយោជិតទាំងអស់ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមប្រកាសក្រសួង ។

៧- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកកុំកាត់ប្រាក់រង្វាន់ប្រចាំខែផ្នែកប្រធានក្រុម ផ្នែកជាង និងកម្មករនិយោជិតដែលមានប្រាក់រង្វាន់លើសពី ០៥ ដុល្លារ នៅពេលដែលសុំច្បាប់។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់។

៨- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដល់តំណាងកម្មករ ថ្នាក់ដឹកនាំសហជីពមូលដ្ឋាន និងសកម្មជននៅពេលដែលមានលិខិតអញ្ជើញចូលរួមសិក្ខាសាលា ឬប្រជុំផ្សេងៗពីសហព័ន្ធ អង្គការ ក្រសួងការងារ ឬស្ថាប័នផ្សេងៗ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនអនុញ្ញាតតែក្នុងករណីដែលមានលិខិតពីក្រសួងការងារតែប៉ុណ្ណោះ។

៩- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកអនុគ្រោះដល់កម្មករនិយោជិត ដែលមកធ្វើការយឺតម៉ោង ដោយសារស្ទះចរាចរណ៍បែកកង់ម៉ូតូ ឬមានបញ្ហាផ្សេងៗ នៅតាមផ្លូវ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់។

១០- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកទទួលខុសត្រូវ នៅពេលដែលកម្មករនិយោជិតឈឺ ដួលសន្លប់នៅក្នុងរោងចក្រ ត្រូវបញ្ជូនទៅមន្ទីរពេទ្យទោះជាគ្រោះថ្នាក់ការងារ និងមិនមែនគ្រោះថ្នាក់ការងារក៏ដោយ ក្រុមហ៊ុនត្រូវតែចេញថ្លៃព្យាបាល។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់។

១១- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកកុំកំណត់ខោអាវឱ្យកម្មករនិយោជិតដេរច្រើនហួសហេតុពេក។ ក្នុងករណីកម្មករនិយោជិតដេរមិនបានគ្រប់ចំនួនកំណត់ ឬមិនស្មើនឹងចំនួនប្រាក់ឈ្នួលគោល ស្នើក្រុមហ៊ុនកុំធ្វើការព្រមានកម្មករនិយោជិត។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនរក្សាតាមគោលការណ៍ចាស់។

១២- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកកុំបញ្ចប់កិច្ចសន្យាកម្មករនិយោជិត ដែលមានកិច្ចសន្យាខ្លីៗ ដោយគ្មានមូលហេតុត្រឹមត្រូវ។ នៅពេលបន្តកិច្ចសន្យាថ្មី ស្នើក្រុមហ៊ុនកុំឱ្យកម្មករនិយោជិតឈប់សម្រាក គឺបន្តកិច្ចសន្យាឱ្យកម្មករនិយោជិតធ្វើការជាប់រហូត ហើយកុំធ្វើការសាកល្បងកម្មករនិយោជិតសារជាថ្មីទៀត។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់។

១៣- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល ១០០ ភាគរយ និងអត្ថប្រយោជន៍ផ្សេងៗ ១០០ ភាគរយ ក្នុងអំឡុងពេលកម្មករធ្វើការតវ៉ា។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២២ កប/ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ (អាណត្តិទី១៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) លេខ ១២៧០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ការិយាល័យវិវាទទី១ នៃនាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១៨០/១៦ សបក/វិវាទ ស្តីពីការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក ការិយាល័យវិវាទបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ១៩ ចំណុច ជាលើកចុងក្រោយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ១៣ ចំណុច។ ចំណុចមិនសះជា ចំនួន ១៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង លេខ ១២៧០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១៣ ចំណុច នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ១៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ០១ ចំណុច គឺ ចំណុចវិវាទទី៩ ហើយភាគីទាំងពីរបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសូរសេរចំណុចព្រមព្រៀងនេះ ក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាល។ ទន្ទឹមនឹងនោះ ភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទ ចំនួន ១១ ចំណុច គឺចំណុចវិវាទទី២, ទី៣, ទី៤, ទី៥, ទី៦, ទី៧, ទី៨, ទី១០, ទី១១, ទី១២ និងទី១៣។ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាតែចំណុចវិវាទដែលនៅសល់ ចំនួន ០១ ចំណុចតែប៉ុណ្ណោះ គឺចំណុចវិវាទទី១។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសយកសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ផ្ដល់ឯកសារ និងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ទៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ទីតាំងទី២ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំផ្ទេរសិទ្ធិជូនលោក តាំង ម៉េង (ទីប្រឹក្សាក្រុមហ៊ុន) លោក ឡេង មិនា (ប្រធានរដ្ឋបាល) និងកញ្ញា ចាន់ សំណោង (ជំនួយការរដ្ឋបាល)។

២- លិខិតលេខ ១០៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការបញ្ចប់សំណុំរឿងលេខ ១៩៥/១៦-អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ២។

៣- លិខិតចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំដកពាក្យបណ្ដឹង និងបញ្ចប់សំណុំរឿងវិវាទការងាររួមរបស់សំណុំរឿងលេខ ១៩៥/១៦ ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ២។

៤- តារាងបែងចែកជាងតាមក្រុមរបស់ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ពីរ។

៥- លិខិតជូនដំណឹង ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ស្ដីពីការជូនដំណើង ចំនួន ១ ខែ ដើម្បីបញ្ចប់កិច្ចសន្យាថេរវេលាមិនកំណត់ដល់ឈ្មោះ ស៊ឹម សុខា។

៦- បញ្ជីវត្តមានអ្នកចូលរួមផ្សះផ្សាវិវាទការងារនៃក្រុមហ៊ុន អេស អិល ហ្គាមេន នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង II ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦។

៨- លិខិតចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ទីតាំងទីពីរ គោរពជូន ប្រធាននាយកដ្ឋានដោះស្រាយវិវាទការងារ ស្តីពីសេចក្តីជូនដំណឹងស្តីអំពីការបញ្ចប់កិច្ចសន្យាការងារមានថេរវេលាមិនកំណត់ចំពោះលោក ស៊ឹម សុខា អត្តលេខ ១៤៥៤១ ដែលមានមុខងារជាជាងម៉ាស៊ីនដេរ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦។

៩- លិខិតជំទាស់ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ពីរ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំទាស់នូវសារណាក្នុងសំណុំរឿងលេខ ២២០/១៦ នៃក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ពីរ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)។

១០- ឯកសាររូបភាព។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ២០៦/១៦.វិវាទ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចាត់តាំងលោក ស៊ាង យ៉ូត ដើម្បីសម្របសម្រួលលើករណីវិវាទក្រុមហ៊ុន អេស អិល២ ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា)។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី បានចុះបញ្ជិកាលេខ ២៤០៧ ក.ប/វក. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១២។

៣- លិខិតលេខ ១២៦០ ក.ប/អក/វក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ របស់នាយកដ្ឋានវិវាទការងារជម្រាបមក ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២។

៤- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី លេខ ០៤៤/១៦ ក.ប/វ.ប ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦។

៥- ញត្តិទាមទារ និងប្រគល់សិទ្ធិ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់ថ្នាក់ដឹកនាំ និងតំណាងសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន SL Garment Processing (Cambodia) Ltd II គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីសូមពឹងពាក់ និងប្រគល់សិទ្ធិ ដើម្បីដោះស្រាយនូវវិវាទការងាររួមក្នុងក្រុមហ៊ុន SL Garment Processing (Cambodia) Ltd II ទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ ពីដើមរហូតដល់ចប់នីតិវិធី។

៦- លិខិតលេខ ២១១/១៦ ស.ប.ក/វិវាទ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណាលើវិវាទសំណុំរឿងលេខ ២២០/១៦ អេសអិល២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី។

៧- លិខិតចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់នាយកក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ទីតាំងទីពីរ គោរពជូន ប្រធាននាយកដ្ឋានដោះស្រាយវិវាទការងារ ស្តីពីសេចក្តីជូនដំណឹងស្តីអំពីការបញ្ចប់កិច្ចសន្យាការងារមានថេរវេលាមិនកំណត់ ចំពោះលោក ស៊ឹម សុខា អត្តលេខ ១៨៥៤១ ដែលមានមុខងារជាជាងម៉ាស៊ីនដេរ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦។

៨- លិខិតលេខ ១០៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការបញ្ចប់សំណុំរឿងលេខ ១៩៥/១៦ អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ២។

៩- លិខិតចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំដកពាក្យបណ្តឹង និងបញ្ចប់សំណុំរឿងវិវាទការងាររួមរបស់សំណុំរឿងលេខ ១៩៥/១៦ ក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ២។

១០- លិខិតលេខ ១៨៦/១៦.វិវាទ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចាត់តាំងលោក ស៊ាង យ៉ូត ដើម្បីសម្របសម្រួលលើករណីវិវាទក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា)។

១១- ពាក្យបណ្តឹងចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់ឈ្មោះ ស៊ឹម សុខា គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីប្តឹងក្រុមហ៊ុន អេស អិល ២ ស្តីពីបញ្ឈប់ខ្ញុំបាទពីការងារដោយគ្មានមូលហេតុសមរម្យ។

១២- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់ឈ្មោះ ស៊ឹម សុខា គោរពជូន សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីសូមផ្ទេរសិទ្ធិជូនសម្ព័ន្ធសហជីពស៊ីខៅឌី ដើម្បីដោះស្រាយជូនខ្ញុំនូវគ្រប់ដំណើរការនីតិវិធីទាំងក្នុងក្រុមហ៊ុនផ្ទាល់ នៅនាយកដ្ឋានវិវាទការងារ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល រួមទាំងក្នុង និងក្រៅប្រព័ន្ធតុលាការរហូតដល់ចប់រឿងក្តី។

១៣- កាតសំគាល់ខ្លួនរបស់ឈ្មោះ ស៊ឹម សុខា។

១៤- លិខិតអះអាងបញ្ជាក់របស់កម្មករនិយោជិតក្រុម B និងក្រុម C នៃក្រុមហ៊ុន SL2 Garment Processing Cambodia Ltd. បញ្ជាក់ថា ជាងម៉ាស៊ីនឈ្មោះ ស៊ឹម សុខា ពិតជាជាងម៉ាស៊ីនជួសជុលម៉ាស៊ីននៅក្រុម B និងក្រុម C ។

១៥- លិខិតលេខ ២១៤/១៦ ស.ប.ក/វិវាទ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំទាស់ឯកសាររបស់និយោជក និងយោបល់ការពារក្នុងសំណុំរឿងលេខ ២២០/១៦ អេសអិល២ ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) លេខ ១២៧០ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេស អិល ហ្គាមេន ប្រូសេសស៊ីង (ខេមបូឌា) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១២៤៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១២៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន អេស. អិល. ហ្គាមេន. ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី (តទៅនេះឱ្យហៅថា "ក្រុមហ៊ុន អេស អិល ២") គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់។ នៅថ្ងៃសវនាការ ភាគីនិយោជកបានអះអាងថា បច្ចុប្បន្នក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនប្រហែលជា ៤០០ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល ២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី បានទទួលវិញ្ញាបនបត្រចុះបញ្ជិកាសហជីព លេខ ២៤០៧ ក.ប/វក. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ និងលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ តាមរយៈលិខិតលេខ ១២៦០ ក.ប/អក/វក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយក្នុងនោះរួមមាន ១) ញ្ញាក សែ សម្បុន ជាប្រធាន ២) អ្នកស្រី ស៊ាន សុផល ជាអនុប្រធាន និង ៣) កញ្ញា អន វិឡា ជាលេខាធិការ។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល ២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ក៏បានទទួលវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត តាមរយៈលិខិតលេខ ០៤៤/១៦ ក.ប/វ.ម ចុះថ្ងៃ

ទី២០ ខែមិថុនា ឆ្នាំ២០១៦ ហើយភាពជាតំណាងបំផុតនេះមានសុពលភាពត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

- នៅក្នុងសវនាការ មានវត្តមានរបស់ថ្នាក់ដឹកនាំសហជីពខាងលើ ចំនួន ០២ នាក់ គឺ អ្នកស្រី ស៊ាន សុផល និង កញ្ញា អន វន្ថា ព្រមទាំងកម្មករនិយោជិតម្នាក់ គឺ កម្មករនិយោជិត ស៊ឹម សុខា។

**ចំណុចវិវាទទី ១ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការងារវិញ***

- នៅថ្ងៃសវនាការ ភាគីទាំងពីរបានទទួលស្គាល់ថា ៖
  - កម្មករនិយោជិត ស៊ឹម សុខា មានតួនាទីជាជាងម៉ាស៊ីន ហើយបានចូលបម្រើការងារដំបូងនៅក្នុងក្រុមហ៊ុន នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ ដោយមានប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
  - និយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦។
  - កម្មករនិយោជិត ស៊ឹម សុខា មិនដែលប្រព្រឹត្តកំហុស ឬធ្លាប់ទទួលការព្រមាននោះទេ។
  - កម្មករនិយោជិត ស៊ឹម សុខា ទទួលបានប្រាក់ឈ្នួលគោល ចំនួន ១៦០ ដុល្លារអាមេរិក, ប្រាក់រង្វាន់ធ្វើការទៀងទាត់ ចំនួន ១០ ដុល្លារអាមេរិក, ប្រាក់រង្វាន់អតីតភាពការងារ ចំនួន ០៣ ដុល្លារអាមេរិក និងប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ០៧ ដុល្លារអាមេរិក ក្នុងមួយខែ។
  - កម្មករនិយោជិត ស៊ឹម សុខា មិនទាន់ទទួលយកប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារ និងប្រាក់ឈ្នួលចុងក្រោយនៅឡើយទេ។
  - និយោជកឯកភាពទូទាត់ប្រាក់បំណាច់បណ្ដេញចេញ, ប្រាក់សោហ៊ុយជម្ងឺចិត្ត ប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ និងប្រាក់ឈ្នួលចុងក្រោយជូនកម្មករនិយោជិត ស៊ឹម សុខា សម្រាប់ការផ្ដាច់កិច្ចសន្យាការងារនេះ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ឹម សុខា ចូលធ្វើការ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា និយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ដោយមិនមានមូលហេតុត្រឹមត្រូវ ព្រោះគាត់ មិនដែលប្រព្រឹត្តកំហុស ឬធ្លាប់ទទួលការព្រមានពីមុនមកនោះទេ។ ហេតុនេះ យោងតាមច្បាប់ស្ដីពីការងារ និងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលមុនៗ ដូចជាសេចក្ដីបង្គាប់លេខ ០០៥/១៦ វ៉ាយអិលធី អ៊ិនធើណេសិនណល និយោជកត្រូវទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការងារវិញបានទេ ដោយមូលហេតុថា ៖

- កម្មករនិយោជិតផ្នែកដេរនៅក្នុងក្រុម D និង E ជាក្រុមដែលកម្មករនិយោជិត ស៊ីម សុខា ត្រូវត្រួតពិនិត្យ និងជួសជុលម៉ាស៊ីនដេរជាប្រចាំនោះ មិនមានកម្មករនិយោជិតទៀតទេ ពីព្រោះពួកគាត់បានលាឈប់អស់ភាគច្រើន ហើយមួយចំនួនទៀតដែលនៅសល់ត្រូវបានបញ្ចូលទៅក្នុងក្រុមដេរផ្សេង ដូចនេះ ក្រុមដេរ D និង E ដែលកម្មករនិយោជិត ស៊ីម សុខា កាន់ម៉ាស៊ីន មិនមានការងារធ្វើបន្តទៀតទេ ទើបតម្រូវឱ្យនិយោជកបញ្ឈប់គាត់ពីការងារ។
- សមត្ថភាពការងាររបស់កម្មករនិយោជិត ស៊ីម សុខា នៅមានកម្រិតនៅឡើយ បើប្រៀបធៀបនឹងជាងម៉ាស៊ីនដទៃទៀត។
- ជាងម៉ាស៊ីននៅក្នុងក្រុមហ៊ុនមានចំនួនច្រើនពេក បើប្រៀបធៀបនឹងចំនួនម៉ាស៊ីនដែលនៅសល់ជាក់ស្ដែង។
- ការបញ្ឈប់កម្មករនិយោជិត ស៊ីម សុខា គឺជាសិទ្ធិចាត់ចែង និងជាឆន្ទានុសិទ្ធិរបស់និយោជក។

- ភាគីកម្មករនិយោជិតបានឆ្លើយតបថា ៖
  - កម្មករនិយោជិត ស៊ីម សុខា មិនមែនជាជាងម៉ាស៊ីនប្រចាំនៅក្រុម D និង E ទេ ប៉ុន្តែ គាត់ជាជាងម៉ាស៊ីនប្រចាំនៅក្រុម B និង C ហើយសព្វថ្ងៃកម្មករនិយោជិតផ្នែកដេរនៅក្រុម B និង C នៅធ្វើការងារជាធម្មតា។
  - កម្មករនិយោជិត ស៊ាន សុផល ដែលធ្វើការងារនៅក្នុងក្រុម C បានលើកឡើងថា គាត់តែងតែឃើញកម្មករនិយោជិត ស៊ីម សុខា មកត្រួតពិនិត្យ និងជួសជុលម៉ាស៊ីននៅក្នុងក្រុម B និង C ជាញឹកញាប់ ដូច្នេះ គាត់យល់ឃើញថា កម្មករនិយោជិត ស៊ីម សុខា ជាជាងម៉ាស៊ីនប្រចាំនៅក្នុងក្រុម B និង C។ គាត់ធ្លាប់ឃើញកម្មករនិយោជិត ស៊ីម សុខា ទៅត្រួតពិនិត្យ និងជួសជុលម៉ាស៊ីននៅក្នុងក្រុមផ្សេង ហើយក៏ធ្លាប់ឃើញជាងម៉ាស៊ីនដទៃទៀតមកពិនិត្យ និងជួសជុលម៉ាស៊ីននៅក្នុងក្រុម B និង C ដែរ។

- ភាគីនិយោជកក៏បានបញ្ជាក់បន្ថែមទៀតថា ៖
  - ជាធម្មតា នៅក្នុងក្រុមហ៊ុន និយោជកបានធ្វើការបែងចែកក្រុមឱ្យទៅជាងម៉ាស៊ីននីមួយៗ ដើម្បីត្រួតពិនិត្យ និងជួសជុលម៉ាស៊ីនរួចរាល់ហើយ ប៉ុន្តែ នៅពេលខ្លះ ជាងម៉ាស៊ីនដែលនៅក្រុមផ្សេងៗក៏អាចតម្រូវឱ្យពិនិត្យ និងជួសជុលម៉ាស៊ីន ដែលនៅក្បែរៗនោះផងដែរ។ ដូច្នេះ នៅពេលដែលកម្មករនិយោជិត ស៊ីម សុខា ទៅពិនិត្យ និងជួសជុលម៉ាស៊ីននៅក្នុងក្រុម B និង C អាចធ្វើឱ្យកម្មករនិយោជិតធ្វើការនៅទីនោះមានការយល់ច្រឡំថា កម្មករនិយោជិត ស៊ីម សុខា ជាជាងម៉ាស៊ីនប្រចាំនៅក្នុងក្រុម B និង C។
  - មុនពេលកម្មករនិយោជិត ស៊ីម សុខា ត្រូវបានបញ្ឈប់ នៅក្នុងក្រុមហ៊ុនមានក្រុមដេរ ចំនួន ០៧ គឺក្រុម A2, B, C, D, E, H, និង F2 ប៉ុន្តែ នៅខែមិនា ឆ្នាំ២០១៦ ក្រុម E លែងមានកម្មករនិយោជិតធ្វើការងារទៀតហើយ លុះដល់ខែមិថុនា ឆ្នាំ២០១៦ ក្រុម D ក៏លែងមានកម្មករ

និយោជិតធ្វើការងារទៀតដែរ។ ដូច្នេះ សព្វថ្ងៃ នៅក្នុងក្រុមហ៊ុនមានក្រុមដេរចំនួន ០៥ ក្រុម ប៉ុណ្ណោះ គឺ ក្រុម A2, B, C, H, និង F2 ដែលគ្រប់គ្រងដោយជាងម៉ាស៊ីន ចំនួន ០៣ នាក់ និងប្រធានផ្នែក ០១ នាក់។

- ប្រសិនបើកម្មករនិយោជិត សែ សម្បូន (ជាងម៉ាស៊ីន នៅក្រុម B និង C) ដែលជាប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ មានវត្តមាននៅថ្ងៃសវនាការនេះ គាត់ពិតជាអាចបញ្ជាក់បានថា កម្មករនិយោជិត ស៊ឹម សុខា មិនមែនជាជាងម៉ាស៊ីនប្រចាំនៅក្នុងក្រុម B និង C ទេ។

- ភាគីនិយោជកក៏បានលើកឡើងបន្តទៀតថា នៅមុនពេលបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា រយៈពេល ០១ ខែ គឺ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ និយោជកបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅកាន់កម្មករនិយោជិត ស៊ឹម សុខា អំពីការបញ្ឈប់ពីការងារនោះ។ ដោយឡែក កម្មករនិយោជិត ស៊ឹម សុខា មិនព្រមចុះហត្ថលេខាទទួលយកសេចក្ដីជូនដំណឹងនោះទេ។
- ភាគីកម្មករនិយោជិតបានបដិសេធថា និយោជកមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជូនកម្មករនិយោជិត ស៊ឹម សុខា អំពីការបញ្ឈប់ពីការងារនោះទេ គឺនិយោជកបានឱ្យប្រធានក្រុមឈ្មោះ ណៅ វុត្ថា មកប្រាប់ផ្ទាល់មាត់ថា កិច្ចសន្យាការងាររបស់កម្មករនិយោជិត ស៊ឹម សុខា នឹងត្រូវបានកាត់ផ្ដាច់។ ការជូនដំណឹងផ្ទាល់មាត់នេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។
- ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលនូវឯកសារ លិខិតជូនដំណឹងរបស់ក្រុមហ៊ុន អេស អិល ទៅកាន់កម្មករនិយោជិត ស៊ឹម សុខា ចុះនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា ៖ *"...នាយកក្រុមហ៊ុន អេសអិល ហ្គាមេន (ខេមបូឌា) ទីតាំងទីពីរ សូមធ្វើការជូនដំណឹងចំនួន ១ ខែ ដើម្បីបញ្ចប់កិច្ចសន្យាការងារថេរវេលាមិនកំណត់ទៅដល់ឈ្មោះ ស៊ឹម សុខា... ។ ...ថ្ងៃជូនដំណឹងចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ រហូតដល់ថ្ងៃបញ្ចប់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦។"* នៅក្នុងលិខិតជូនដំណឹងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិនិត្យឃើញថា មិនមានហត្ថលេខា ឬស្នាមមេដៃទទួលយកពីសាមីខ្លួនឡើយ។
- ភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលនូវលិខិតជំទាស់ឯកសាររបស់និយោជក និងយោបល់ការពារក្នុងសំណុំរឿងលេខ ២២០/១៦ អេស អិល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ មានខ្លឹមសារថា ៖ *"១.លិខិតជំទាស់លើលិខិតជូនដំណឹង ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ដែលនិយោជកបានជូនដំណឹងដល់ជាងម៉ាស៊ីន ស៊ឹម សុខា ...លិខិតជូនដំណឹងនេះ មានតែហត្ថលេខានាយកក្រុមហ៊ុន និងប្រធានក្រុមជាងឈ្មោះ ណៅ វុត្ថា អត្តលេខ ១៥០២៧ តែប៉ុណ្ណោះ។"*
- ភាគីនិយោជកបានដាក់លិខិតជំទាស់សារណាក្នុងសំណុំរឿងលេខ ២២០/១៦ នៃក្រុមហ៊ុន អេស អិល ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា មានខ្លឹមសារថា ៖ *"...ក្រុមហ៊ុនក៏សំរេចរំលាយកិច្ចសន្យាមានថេរវេលាមិនកំណត់របស់ជាងម៉ាស៊ីនឈ្មោះ ស៊ឹម សុខា ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមុនមួយខែ ហើយលោក ស៊ឹម សុខា ក៏បានទទួលយកលិខិតជូនដំណឹងនោះផងដែរ តែមិនព្រមចុះហត្ថលេខាទទួល ខាងយើងខ្ញុំមានកាមេរ៉ាសុវត្ថិភាពនឹងរូបភាពបញ្ជាក់ផងដែរ។"*

ភាគីនិយោជកក៏បានដាក់រូបភាពពីក្នុងកាមេរ៉ាសុវត្ថិភាពនោះ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាផងដែរ។ តាមរយៈរូបភាពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា និយោជកពិតជាបានហៅលោក ស៊ឹម សុខា ទៅជូនដំណឹងជាលាយលក្ខណ៍អក្សរពីការបញ្ឈប់ពីការងារ ដោយមានវត្តមានរបស់ប្រធានក្រុមរបស់គាត់ចូលរួមផងដែរ ប៉ុន្តែ កម្មករនិយោជិត ស៊ឹម សុខា មិនបានចុះហត្ថលេខាលើលិខិតជូនដំណឹងនោះទេ។

- ភាគីនិយោជកក៏បានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នូវតារាងបែងចែកជាងម៉ាស៊ីនតាមក្រុមរបស់ក្រុមហ៊ុន អេស អិល ដូចខាងក្រោម ៖

| ល.រ | អត្តលេខ | ឈ្មោះ | ភេទ | ផ្នែក | តួនាទី | ទទួលខុសត្រូវក្រុម | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | ១៥១០៤ | ឆោរ ជៀនឈឹង | M | Mechanic | ប្រធានផ្នែក | ទូទៅ | |
| ២ | ១០៤២ | សែ សប្បុន | M | Mechanic | ជាង | B & C | |
| ៣ | ១៣៦០៨ | អុល ផាន់ណោ | M | Mechanic | ជាង | H & C | |
| ៤ | ១៥០២៧ | ហោំ វុត្ថា | M | Mechanic | ប្រធានក្រុម | A2 & F2 | |

នៅក្នុងតារាងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានការចុះហត្ថលេខាទទួលស្គាល់អំពីកម្មករនិយោជិតទីមួយៗ ថា ខ្លួនពិតជាមានតួនាទី និងគ្រប់គ្រងទៅក្រុមដូចមានកំណត់នៅក្នុងតារាងខាងលើ។

- ភាគីកម្មករនិយោជិតបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នូវលិខិតអះអាងបញ្ជាក់ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ ដោយមានស្នាមមេដៃរបស់កម្មករនិយោជិត ចំនួន ៤៦ នាក់ មានខ្លឹមសារថា ៖ *"...យើងខ្ញុំទាំងអស់គ្នា សូមអះអាងបញ្ជាក់ថា ជាងម៉ាស៊ីនឈ្មោះ ស៊ឹម សុខា អត្តលេខ ១៤៥៤១ ពិតជាជាងម៉ាស៊ីន ដែលធ្វើការទទួលខុសត្រូវជួសជុលម៉ាស៊ីននៅក្រុម និងក្រុម ដែលពួកខ្ញុំបានធ្វើការពិតប្រាកដមែន។"* ។
- ភាគីនិយោជកបានជំទាស់លិខិតអះអាងបញ្ជាក់របស់ភាគីកម្មករនិយោជិតខាងលើថា ៖ *"...បើសរុបទាំងពីរក្រុមនេះចូលគ្នា គឺ ក្រុម B & C មានកម្មករ ចំនួន ៩០ នាក់ តែអ្នកផ្តិតមេដៃមានចំនួនត្រឹមតែ ៤៥ នាក់តែប៉ុណ្ណោះ ដោយ ៤០ នាក់ នៃកម្មករដែលផ្តិតមេដៃ គឺជាសកម្មជនរបស់សហជីពស៊ីខៅឌូ។ ម្យ៉ាងវិញទៀត ការងារចាត់ចែង ឬបែងចែកជាង គឺមានតែប្រធានផ្នែក ប្រធានជាង នឹងជាងទេ ដែលដឹងច្បាស់ពីការចាត់ចែងនេះ មិនមែនកម្មករដេរទូទៅដឹងពីការចាត់ចែងនេះទេ។"* ។
- ភាគីកម្មករនិយោជិតក៏បានផ្តល់នូវយោបល់បន្ថែម តាមរយៈលិខិតជំទាស់សារណាតបសំណុំរឿងលេខ ២២០/១៦ នៃក្រុមហ៊ុន អេស អិល ២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ ថា ៖ *"...និយោជកបានហៅប្រធានក្រុមជាងម៉ាស៊ីន និងក្រុមដេរ B និង C មកប្រាប់អំពីការបញ្ឈប់ជាងម៉ាស៊ីន ស៊ឹម សុខា ដោយមានបញ្ជាក់ថា ជាងម៉ាស៊ីន ស៊ឹម សុខា ពិតជាជាងម៉ាស៊ីន កាន់ក្រុមដេរ ក្រុម B និង C ប្រាកដមែន។..."*

THE ARBITRATION COUNCIL

**ចំណុចវិវាទទី ៩ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុគ្រោះដល់កម្មករនិយោជិត ដែលមកធ្វើការយឺតម៉ោង ដោយសារស្ទះចរាចរណ៍ បែកកង់ម៉ូតូ ឬមានបញ្ហាផ្សេងៗ នៅតាមផ្លូវ**

- ភាគីទាំងពីរបានឯកភាពគ្នាថា ជាការអនុវត្តនៅក្នុងក្រុមហ៊ុន បើកម្មករនិយោជិតមកធ្វើការងារយឺតតិចជាង ឬត្រឹម ០៧ នាទី និយោជកនឹងមិនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ទេ។ ក្នុងករណីដែលកម្មករនិយោជិតមកធ្វើការងារយឺត លើសពី ០៧ នាទី នោះនិយោជកឯកភាពពិនិត្យមើលទៅតាមស្ថានភាពជាក់ស្តែងចំពោះករណីមកយឺតនោះ។
- ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាចំណុចវិវាទខាងលើនេះទេ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទារទាំងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបកស្រាយអំពីភាគីដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"*។

នៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រាខាងលើនេះ មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះសំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលអាចធ្វើជាតំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។" (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុ នៅក្នុងក្រុមហ៊ុន អេស អិល២ មានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន អេស អិល ២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ជាសហជីពដែលមានភាពជាតំណាងបំផុតដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត តាមរយៈលិខិតលេខ ០៤៤/១៦ ក.ប/វក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ហើយភាពជាតំណាងបំផុតមានសុពលភាពត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។ សហជីពនេះជាអ្នកនាំវិវាទការងាររួមមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងនេះ។

THE ARBITRATION COUNCIL

ដោយសារសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល ២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី ជាសហជីពដែលមានភាពជាតំណាងបំផុត ហើយភាពជាតំណាងបំផុតនោះ នៅមានសុពលភាពនៅឡើយ ដូចនេះ យោងតាមការបកស្រាយខ្លឹមសារនៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន អេសអិល ២ ហ្គាមិន ប្រូសេសស៊ីង (ខេមបូឌា) អិលធីឌី មានសិទ្ធិក្នុងការតំណាងឱ្យកម្មករនិយោជិត នៃក្រុមហ៊ុន អេស អិល ២ ដើម្បីនាំយកវិវាទការងាររួមក្នុងការដោះស្រាយ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការងារ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការងារ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញដែរឬទេ?

តាមរយៈអង្គហេតុខាងលើ កម្មករនិយោជិត ស៊ឹម សុខា មានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ហើយគាត់ត្រូវបាននិយោជកបញ្ឈប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦។

មាត្រា ៧៤ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន។ ការរំលាយកិច្ចសន្យានេះ ត្រូវអនុវត្តទៅតាមរបៀបឱ្យដំណឹងមុនជាលាយលក្ខណ៍អក្សរ ដែលភាគីមានបំណងចង់រំលាយកិច្ចសន្យា ត្រូវឱ្យទៅភាគីម្ខាងទៀត។*

*ក៏ប៉ុន្តែ គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបាន ដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬឥរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមឡើយ។*"។

ផ្អែកលើខ្លឹមសារនៃមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមានសិទ្ធិបញ្ឈប់កម្មករនិយោជិតដោយឆន្ទៈខ្លួនឯងបាន ដោយផ្តល់ដំណឹងដល់កម្មករនិយោជិត ដោយបញ្ជាក់ពីហេតុផលសមរម្យ ទាក់ទងនឹងសម្បទា ឬឥរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាសរបស់គ្រឹះស្ថាន ឬរបស់ក្រុម។ *(សូមមើលសេចក្តីសម្រេចអាជ្ញាកណ្តាលលេខ ៥១/០៨-អេអេសឌី ហេតុផលនៃចំណុចវិវាទទី៣, លេខ ៦០/០៨-ភីស៊ីស៊ីអេស ហេតុផលនៃចំណុចវិវាទទី៦, លេខ ២០៥/១២-ស៊ូ តុងហ្វាង ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១១៦/១៥-ព្រលានយន្តហោះអន្តរជាតិសៀមរាប ហេតុផលនៃចំណុចវិវាទទី៥ និងលេខ ១៤២/១៦-ហ៊្សិណោ ដាយដុង (ខេមបូឌា) អេឡិចត្រូនិច ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានអះអាងថា និយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ដោយមូលហេតុថា កម្មករនិយោជិតផ្នែកដេរនៅក្រុម D និង E (ក្រុមដែលកម្មករនិយោជិត ស៊ឹម សុខា ធ្វើការត្រួតពិនិត្យ និងជួសជុលម៉ាស៊ីនដេរជាប្រចាំ) លែងមានតទៅទៀតហើយ ដូច្នេះ និយោជកមិនមានការងារឱ្យគាត់ធ្វើបន្តទៀតទេ។

កម្មករនិយោជិតបានបដិសេធថា កម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីនប្រចាំ នៅក្រុម B និង C ហើយសព្វថ្ងៃកម្មករនិយោជិតផ្នែកដេរនៅក្រុម B និង C នៅធ្វើការងារជាធម្មតា។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៧៩/០៥-អេវើរហ្គ្រីន, លេខ ១០១/០៨-ជីឌីអុីម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទឹកថ្លា ផ្លាហ្សា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី១៨ និងលេខ ១៤៨/១១-ដាយ យ៉ាំង, លេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាងជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញ វែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ័បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤ និងលេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ០៣២/១៦-អុីធើនិធិ ក្លូប៊ល ស្ព័តធីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

ក្នុងករណីនេះ និយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវតារាងបែកចែកការងាររបស់ជាងម៉ាស៊ីន ដោយមានការចុះហត្ថលេខាទទួលស្គាល់អំពីជាងម៉ាស៊ីននីមួយៗថា ពួកគាត់ពិតជាមានតួនាទី និងគ្រប់គ្រងទៅក្រុមដូចមានកំណត់នៅក្នុងតារាងនោះមែន។ ដោយឡែក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តារាងនេះ គឺជាតារាងបែកចែកការងារ នៅក្រោយពេលដែលនិយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ពីព្រោះ ការបែងចែកការងារនៅក្នុងតារាងនោះ គឺសម្រាប់ជាងម៉ាស៊ីន ចំនួន ០៤ នាក់ ប៉ុណ្ណោះ ដោយមិនមានឈ្មោះរបស់កម្មករនិយោជិត ស៊ឹម សុខា នៅក្នុងតារាងទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកគួរតែបង្ហាញនូវតារាងបែងចែកការងារ នៅមុនពេលកម្មករនិយោជិត ស៊ឹម សុខា ត្រូវបាននិយោជកបញ្ឈប់ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីន នៅក្នុងក្រុមដេរណាមួយឱ្យប្រាកដ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តារាងបែងចែកការងារនេះ មិនអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានបានថា កម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីននៅក្រុម D និង E ដូចដែលនិយោជកបានលើកឡើងនោះឡើយ។

ទន្ទឹមនឹងនេះ កម្មករនិយោជិតក៏បានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវលិខិតអះអាងបញ្ជាក់របស់កម្មករនិយោជិតដែលធ្វើការងារនៅក្រុម B និង C ថា កម្មករនិយោជិត ស៊ឹម សុខា ពិតជាជាងម៉ាស៊ីនប្រចាំនៅក្រុម B និង C មែន។ ដោយឡែក នៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សម្គាល់ឃើញថា ការអះអាងរបស់កម្មករនិយោជិតនៅក្នុងសវនាការ ដែលថាកម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីនប្រចាំនៅក្រុម B និង C គឺមិនមានភាពច្បាស់លាស់នោះឡើយ ព្រោះជាការយល់ឃើញផ្ទាល់ខ្លួន ដោយសារតែពួកគាត់តែងឃើញកម្មករនិយោជិត ស៊ឹម សុខា មកត្រួតពិនិត្យ និងជួសជុលម៉ាស៊ីននៅក្នុងក្រុម B និង C ជាញឹកញាប់។ ក្នុងករណីនេះ និយោជកបានបញ្ជាក់ថា និយោជកបានធ្វើការបែងចែកក្រុមឱ្យទៅជាងម៉ាស៊ីននីមួយៗ ដើម្បីត្រួតពិនិត្យ និងជួសជុលម៉ាស៊ីនរួចរាល់ហើយ

ប៉ុន្តែ នៅពេលខ្លះ ជាងម៉ាស៊ីនដែលនៅក្រុមផ្សេងៗ ក៏អាចត្រូវឱ្យពិនិត្យ និងជួសជុលម៉ាស៊ីន ដែលនៅក្បែរៗនោះផងដែរ។កម្មករនិយោជិតក៏បានទទួលស្គាល់ថា ពួកគាត់ក៏ធ្លាប់បានឃើញកម្មករនិយោជិត ស៊ឹម សុខា ទៅត្រួតពិនិត្យ និងជួសជុលម៉ាស៊ីននៅក្រុមផ្សេង ហើយក៏ធ្លាប់ឃើញជាងម៉ាស៊ីនដទៃទៀត ទៅធ្វើការនៅក្រុម B និង C ផងដែរ។ តាមរយៈការអះអាងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនបានដឹងច្បាស់លាស់ពីការបែងចែកការងាររបស់ជាងម៉ាស៊ីននៅក្នុងក្រុមហ៊ុននោះឡើយ។ ដូចនេះ ទោះបីជាពួកគាត់បានផ្តល់នូវការអះអាងតាមរយៈស្នាមមេដៃថា កម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីនប្រចាំនៅក្នុងក្រុម B និង C ក៏ដោយ ក៏លិខិតអះអាងខាងលើនេះ មិនអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសន្និដ្ឋានបានថា កម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីនប្រចាំនៅក្នុងក្រុម B និង C នោះឡើយ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងករណីនេះ ទាំងភាគីកម្មករនិយោជិត និងភាគីនិយោជក មិនបានបំពេញនូវបន្ទុកភស្តុតាង ដែលអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿបានថា កម្មករនិយោជិត ស៊ឹម សុខា ជាជាងម៉ាស៊ីន នៅក្នុងក្រុមណាមួយច្បាស់នោះទេ។

យោងតាមការបកស្រាយខាងលើ ការទាមទារឱ្យកម្មករនិយោជិត ស៊ឹម សុខា ចូលធ្វើការងារវិញនៅក្រុម B និង C គឺមិនមានមូលដ្ឋានគាំទ្រច្បាស់លាស់នោះឡើយ។ ចំណែកឯ និយោជកក៏មិនមានលទ្ធភាពក្នុងការបង្ហាញថា និយោជកមានហេតុផលសមរម្យក្នុងការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ដោយសារក្រុមដេរ ដែលគាត់កាន់ (ក្រុម D និង E) លែងមានទៀតហើយនោះដែរ។ ទន្ទឹមនឹងនេះ និយោជកបានអះអាងថា ការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា គឺធ្វើឡើងដោយឆន្ទៈរបស់និយោជក ហើយនិយោជកក៏ទទួលស្គាល់ថា កម្មករនិយោជិត ស៊ឹម សុខា មិនដែលបានប្រព្រឹត្តកំហុស ឬទទួលបាននូវការព្រមានណាមួយទេ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់ដោយឆន្ទៈរបស់និយោជក គឺមិនពាក់ព័ន្ធនឹងហេតុផលសមរម្យណាមួយទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលលើភាពចាំបាច់នៃដំណើរការរបស់ក្រុមហ៊ុន ក្នុងការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា នោះទេ។

នៅក្នុងសំណុំរឿងនេះ និយោជកបានប្រកាន់ជំហរថា និយោជកនឹងមិនទទួលយកកម្មករនិយោជិតឱ្យចូលធ្វើការងារវិញទេ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជក មិនមានលក្ខណៈចុះសម្រុងនឹងគ្នានោះទេ ព្រោះនិយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ពីការងារ ដោយឆន្ទៈរបស់និយោជកតែម្ខាង។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារស្របតាមច្បាប់ស្តីពីការងារ ជូនកម្មករនិយោជិត ស៊ឹម សុខា ដូចខាងក្រោម ៖

**១- ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន**

មាត្រា ៧៥ នៃច្បាប់ស្តីពីការងារខាងលើ ចែងថា ៖ "*ថិរវេលាដែលត្រូវឱ្យដំណឹងមុន ត្រូវកំណត់ជាអប្បបរមា ដូចតទៅ ៖*

- *ប្រាំពីរថ្ងៃ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសតិចជាងប្រាំមួយខែ។*
- *ដប់ប្រាំថ្ងៃ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាស ពីប្រាំមួយខែ ដល់ពីរឆ្នាំ។*

- *មួយខែ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសលើសពីពីរឆ្នាំ រហូតដល់ប្រាំឆ្នាំ... ។*
- *ពីរខែ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសលើសពីប្រាំឆ្នាំ រហូតដល់ដប់ឆ្នាំ ។*
- *បីខែ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសលើសពីដប់ឆ្នាំ ។"*

មាត្រា ៧៧ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ "*ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈនៃនិយោជកតែឯកឯងគ្មានឱ្យដំណឹងមុន ឬ មិនគោរពតាមរយៈពេលនៃការឱ្យដំណឹងមុន ត្រូវឱ្យនិយោជកចេញប្រាក់ទូទាត់ដល់កម្មករនិយោជិតមានចំនួនស្មើគ្នានឹងប្រាក់ឈ្នួល ហើយនិងអត្ថប្រយោជន៍គ្រប់ប្រភេទ ដែលកម្មករនិយោជិតត្រូវបានក្នុងរយៈពេលឱ្យដំណឹងមុន ដែលគេមិនបានគោរពត្រឹមត្រូវ ។"*

នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិត ស៊ឹម សុខា បានចូលបម្រើការងារពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ ហើយត្រូវបាននិយោជកបញ្ឈប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៦ មានន័យថា គាត់បានធ្វើការងារបានជិតរយៈពេល ០៣ ឆ្នាំ ហើយ ។ បើយោងតាមមាត្រា ៧៤ និង៧៥ នៃច្បាប់ស្តីពីការងារខាងលើ និយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរ រយៈពេល ០១ ខែ មុនពេលបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ។

និយោជកបានអះអាងថា និយោជកបានជូនដំណឹងជាលាយលក្ខណ៍អក្សរជូនកម្មករនិយោជិត ស៊ឹម សុខា រយៈពេល ០១ ខែ មុនថ្ងៃបញ្ឈប់ពីការងារ ប៉ុន្តែ កម្មករនិយោជិត ស៊ឹម សុខា មិនព្រមចុះហត្ថលេខាលើលិខិតជូនដំណឹងនោះ ។ រីឯកម្មករនិយោជិតបានបដិសេធថា និយោជកបានជូនដំណឹងពីការបញ្ឈប់ដោយផ្ទាល់មាត់ តាមរយៈប្រធានក្រុម ណៅ វុត្ថា តែមិនបានធ្វើជាលិខិតលាយលក្ខណ៍អក្សរទេ ។

ចំណុចវិវាទនេះ គឺមានពាក់ព័ន្ធនឹងបន្ទុកភស្តុតាងរបស់ភាគីដែលអះអាង ឬចោទប្រកាន់ ។ *(សូមមើលការបកស្រាយទាក់ទងនឹងបន្ទុកភស្តុតាងខាងលើ)*

ក្នុងករណីនេះ ភាគីកម្មករនិយោជិតគ្រាន់តែបានអះអាងថា នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ប្រធានក្រុម ណៅ វុត្ថា បានជូនដំណឹងដោយផ្ទាល់មាត់ពីការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ប៉ុន្តែ កម្មករនិយោជិតមិនបានផ្តល់នូវភស្តុតាងណាមួយដើម្បីគាំទ្រនូវការលើកឡើងនេះទេ ។ ផ្ទុយទៅវិញ និយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវរូបថតដែលបានផ្តិតចេញពីកាម៉េរ៉ាសុវត្ថិភាព ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួនដែលថា កម្មករនិយោជិត ស៊ឹម សុខា ពិតជាត្រូវបាននិយោជកជូនដំណឹងជាលាយលក្ខណ៍អក្សរពីការបញ្ឈប់ពីការងារ ប៉ុន្តែ កម្មករនិយោជិត ស៊ឹម សុខា មិនបានចុះហត្ថលេខាលើលិខិតជូនដំណឹងនោះ ហើយមានតែប្រធានក្រុមហ៊ុន និងប្រធានក្រុម ណៅ វុត្ថា ដែលចុះហត្ថលេខានោះ ។ យោងតាមការអះអាងរបស់និយោជក ព្រមទាំងភស្តុតាងដែលជារូបថតនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ត្រឹមត្រូវតាមច្បាប់ស្តីពីការងាររួចរាល់ហើយ ។

ហេតុនេះ កម្មករនិយោជិត ស៊ឹម សុខា មិនមានសិទ្ធិទទួលបានប្រាក់បំណាច់ទូទាត់ជំនួសការជូនដំណឹងមុន តាមមាត្រា ៧៥ និងមាត្រា ៧៧ នៃច្បាប់ស្តីពីការងារនោះទេ ។

២-ប្រាក់បំណាច់បណ្តេញចេញ ៖

មាត្រា ៨៩ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ប្រសិនបើកិច្ចសន្យាការងារត្រូវបញ្ឈប់ដោយឆន្ទៈរបស់និយោជកតែម្ខាង វៀរលែងតែក្នុងករណីដែលកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកត្រូវតែឱ្យទៅកម្មករនិយោជិតដែលខ្លួនបញ្ឈប់ ... នូវប្រាក់បំណាច់បណ្តេញចេញ ដែលមានកំរិតដូចតទៅ ៖*

- *ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ចំនួនប្រាំពីថ្ងៃ ចំពោះកម្មកនិយោជិតដែលបានធ្វើការជាប់ជានិច្ច ចាប់ពីប្រាំមួយខែ ទៅដល់ដប់ពីរខែ ។*
- *ចំពោះរយៈពេលធ្វើការលើសពីដប់ពីរខែទៅ ប្រាក់បំណាច់បណ្តេញចេញត្រូវគណនា ស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួនដប់ប្រាំថ្ងៃក្នុងមួយឆ្នាំការងារ ។ ប្រាក់បំណាច់បណ្តេញចេញអតិបរមា មិនអាចលើសប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំប្រាំមួយខែទេ ។ បើចំរយៈពេលធ្វើការលើសពីមួយឆ្នាំ ហើយមានប្រភាគចំរយៈពេលធ្វើការចាប់ពីប្រាំមួយខែឡើង ត្រូវគិតស្មើនឹងមួយឆ្នាំពេញ ។..."*

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ពីការងារ គឺមិនផ្អែកលើកំហុសរបស់កម្មករនិយោជិតនោះទេ តែនិយោជកបញ្ឈប់កម្មករនិយោជិតដោយឆន្ទៈផ្ទាល់ខ្លួន ។ ហេតុនេះ យោងតាមមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ កម្មករនិយោជិត ស៊ឹម សុខា មានសិទ្ធិទទួលបានប្រាក់បំណាច់បណ្តេញចេញ ស្របតាមអតីតភាពការងារដែលគាត់បានធ្វើជាក់ស្តែង ។

<u>ការគណនាប្រាក់បំណាច់បណ្តេញចេញ</u>

នៅក្នុងសេចក្តីសម្រេចអាជ្ញាកណ្តាលលេខ ៥១/០៤-សាំហាន់ ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"ក្នុងការសម្រេចអំពីរបៀបគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ តាមគោលបំណងមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានណែនាំដោយមាត្រា ១៦៨ ដែលតម្រូវថា ការគណនាប្រាក់ក្នុងអំឡុងពេលឈប់សំរាក ដោយផ្អែកលើមូលដ្ឋានប្រាក់ដែលរកបានជាមធ្យមក្នុងរយៈពេល ១២ ខែ ។ ឧទាហរណ៍ កម្មករម្នាក់ដែលមានអតីតភាពការងារ ១៣ ខែ មានសិទ្ធិទទួលបានប្រាក់ឈ្នួល និងផលប្រយោជន៍បន្ទាប់បន្សំ ចំនួន ១៥ ថ្ងៃ ដោយយោងតាមច្បាប់មាត្រា ៨៩ ត្រូវបានគណនា ដូចខាងក្រោម ៖*

*ប្រាក់ឈ្នួលសរុបទាំងអស់ដែលរួមទាំងប្រាក់ការងារបន្ថែមម៉ោង និងប្រាក់រង្វាន់ដែលកម្មករនោះ ទទួលបានក្នុងរយៈពេល ១២ ខែ មុនពេលបណ្តេញចេញ ចែកនឹង ១២ គឺជាប្រាក់ខែជាមធ្យមភាគប្រចាំខែ ។ ប្រាក់ខែជាមធ្យមភាគប្រចាំខែ ចែកនឹង ២៦ គឺជាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃនេះ គឺជាមូលដ្ឋាននៃការគិតប្រាក់បំណាច់បណ្តេញចេញ ។" (សូមមើលបន្ថែមនៅក្នុងសេចក្តីសម្រេចអាជ្ញាកណ្តាលសំណុំរឿងលេខ ២៧/០៤-អឹមអេស អាយ ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវផ្អែកទៅតាមមធ្យមភាគប្រាក់ឈ្នួលដែលបានទទួលក្នុងរយៈពេល ១២ ខែ ចុងក្រោយ ។

THE ARBITRATION COUNCIL

៣- សោហ៊ុយជម្ងឺចិត្ត ៖

មាត្រា ៩១ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ "*ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីមួយ ដោយគ្មានហេតុផលត្រឹមត្រូវនោះ អាចបើកសិទ្ធិឱ្យភាគីម្ខាងទៀតទារសងសោហ៊ុយជម្ងឺចិត្តបាន ។*

*សោហ៊ុយជម្ងឺចិត្តនេះ មិនត្រូវច្រឡំគ្នាជាមួយនឹងប្រាក់បំណាច់ទូទាត់ជូសការឱ្យដំណឹងមុន ឬជាមួយនឹងប្រាក់បំណាច់បណ្ដេញចេញ ។*

*កម្មករនិយោជិតអាចទាមទារប្រាក់បំណាច់បើកផ្ដាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្ដេញចេញ ។ ក្នុងករណីនេះ កម្មករនិយោជិតត្រូវបានរួចពីកាតព្វកិច្ចដែលត្រូវផ្ដល់ភស្ដុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន ។*"

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកបានបញ្ឈប់កម្មករនិយោជិត ស៊ឹម សុខា ដោយមិនមានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោលទៅលើភាពចាំបាច់នៃដំណើររបស់ក្រុមហ៊ុន ដូចមានចែងនៅក្នុងមាត្រា ៧៤ នៃច្បាប់ស្ដីពីការងារនោះទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិត ស៊ឹម សុខា មានសិទ្ធិទទួលបានសោហ៊ុយជម្ងឺចិត្ត ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្ដេញចេញ ស្របតាមមាត្រា ៩១ នៃច្បាប់ស្ដីពីការងារខាងលើ ។

៤- ប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ ៖

មាត្រា ១៦៦ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ " *លើកលែងតែមានបញ្ញត្តិ ក្នុងអនុសញ្ញារួម ឬកិច្ចសន្យាការងាររៀងខ្លួន ដែលផ្ដល់អត្ថប្រយោជន៍ច្រើនជាងនោះ កម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ដែលនិយោជកត្រូវចេញឱ្យ ។ ឯថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះក្នុងរយៈពេលធ្វើការមួយខែជាប់ ។*

.....

*ថិរវេលានៃថ្ងៃឈប់សំរាកដែលមានកំរិតដូចខាងលើនេះ ត្រូវបន្ថែមឱ្យកម្មករនិយោជិតតាមអតីតភាពរបស់ខ្លួនក្នុងសហគ្រាសដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបានបីឆ្នាំ ។*"

កថាខណ្ឌទី២ មាត្រា ១៦៧ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ "*...ក្នុងករណីដែលមានផ្ដាច់ ឬចប់កិច្ចសន្យាមុនដែលកម្មករនិយោជិតទទួលសិទ្ធិបានឈប់សំរាកនោះ ត្រូវសងប្រាក់បំណាច់ទៅកម្មករនិយោជិតនោះតាមកំរិតក្នុងមាត្រា ១៦៦ ខាងលើ ។... ។*"

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិត ស៊ឹម សុខា មានសិទ្ធិទទួលបានប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ ដែលមិនទាន់បានប្រើប្រាស់អស់មុនពេលបញ្ចប់កិច្ចសន្យាស្របតាមមាត្រា១៦៦ នៃច្បាប់ស្ដីពីការងារនេះ ។

<u>ការគណនាប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ</u>

មាត្រា ១៦៨ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ "*និយោជកត្រូវបង់ឱ្យកម្មករនិយោជិតនៅពេលមុនថ្ងៃឈប់សំរាកនូវប្រាក់វិភាជន៍ យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួល បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍ បំណាច់ គិតទាំងតំលៃវត្ថុដែលផ្ដល់ឱ្យផង ដោយមិនគិតពីបំណាច់សងសោហ៊ុយដែលកម្មករនិយោជិតបានបើករួចមកហើយ*

THE ARBITRATION COUNCIL

*ក្នុងរយៈពេលដប់ពីរខែមុនថ្ងៃឈប់សំរាក ។ ប្រាក់វិភាជន៍នេះ ក្នុងករណីណាក៏ដោយមិនត្រូវឱ្យតិចជាងវិភាជន៍ ដែលកម្មករនិយោជិតត្រូវបើកកាលបើខ្លួនបានធ្វើការដោយទៀងទាត់នោះឡើយ ។"*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ១៦៨ នៃច្បាប់ស្តីពីការងារនេះថា ៖ *"និយោជកត្រូវធ្វើការគណនាប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលសរុបនៃរយៈពេលដប់ពីរខែចុងក្រោយ ដែលកម្មករនិយោជិតធ្វើបានមកចែកនឹងដប់ពីរ ដើម្បីរកប្រាក់មធ្យមក្នុងមួយខែ ។ បន្ទាប់មកយកប្រាក់ឈ្នួលមធ្យមក្នុងមួយខែនេះ មកចែកនឹង ២៦ ដើម្បីរកប្រាក់ឈ្នួលមធ្យមក្នុងមួយថ្ងៃ ដើម្បីប្រើជាប្រាក់ឈ្នួល ធ្វើជាមូលដ្ឋានសម្រាប់បង់ឱ្យកម្មករនិយោជិតក្នុងពេលឈប់សម្រាកប្រចាំឆ្នាំ ។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៣/០៨-អ៊ីមវ៉េ១ ហេតុផលនៃចំណុចវិវាទទី៧ និង លេខ ២៥/០៨-អេអេសឌី ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវផ្អែកទៅតាមមធ្យមភាគប្រាក់ឈ្នួលដែលបានទទួលក្នុងរយៈពេល ១២ ខែ ចុងក្រោយ ។

៥- ប្រាក់ឈ្នួលចុងក្រោយ ៖

មាត្រា ១១៦ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"...ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និងប្រាក់បំណាច់គ្រប់ប្រភេទ ត្រូវបើកក្នុងរយៈពេលសែសិបប្រាំបីម៉ោង បន្ទាប់ពីថ្ងៃឈប់ធ្វើការ "* ។

ក្នុងករណីនេះ កម្មករនិយោជិត ស៊ឹម សុខា មិនទាន់ទទួលបាននូវប្រាក់ឈ្នួលចុងក្រោយនៅឡើយទេ ។ ហេតុនេះ យោងតាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចក្នុងការបើកប្រាក់ឈ្នួលចុងក្រោយ ជូនកម្មករនិយោជិត ស៊ឹម សុខា ស្របតាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ឹម សុខា ឱ្យចូលធ្វើការ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញ ។
- បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត ស៊ឹម សុខា ដូចខាងក្រោម ៖
    - ប្រាក់បំណាច់បណ្តេញចេញ តាមមាត្រា៨៩ នៃច្បាប់ស្តីពីការងារ ។
    - សោហ៊ុយជម្ងឺចិត្ត តាមមាត្រា៩១ នៃច្បាប់ស្តីពីការងារ ។
    - ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ តាមមាត្រា១៦៦ និងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ ។
    - ប្រាក់ឈ្នួលចុងក្រោយ តាមមាត្រា១១៦ នៃច្បាប់ស្តីពីការងារ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទទី ១ ៖

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកទទួលយកកម្មករនិយោជិត ស៊ឹម សុខា ចូលធ្វើការ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ រហូតដល់ថ្ងៃចូលធ្វើការវិញ ។
- បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិត ស៊ឹម សុខា ដូចខាងក្រោម ៖
    - ប្រាក់បំណាច់បណ្តេញចេញ តាមមាត្រា៨៩ នៃច្បាប់ស្តីពីការងារ ។
    - សោហ៊ុយជម្ងឺចិត្ត តាមមាត្រា៩១ នៃច្បាប់ស្តីពីការងារ ។
    - ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ តាមមាត្រា១៦៦ និងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ ។
    - ប្រាក់ឈ្នួលចុងក្រោយ តាមមាត្រា១១៦ នៃច្បាប់ស្តីពីការងារ ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ទូចហ៊ុន**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ុន គឹមស៊ាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL